# គោលការណ៍ទីក្រុងប៉ារីស
# ស្តីពី
# ស្ថាប័នជាតិសិទ្ធិមនុស្ស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

៦០

សេចក្តីប្រកាស
ជាសកល
ស្តីពីសិទ្ធិមនុស្ស
១៩៤៨-២០០៨

# សេចក្តីថ្លៃថ្នូរ និង
# យុត្តិធម៌សំរាប់ទាំងអស់គ្នា


អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា – ភ្នំពេញ

# គោលការណ៍ស្ដីពីឋានៈនៃស្ថាប័នជាតិ ដើម្បីសិទ្ធិមនុស្ស

## ជាទូទៅគេហៅថា " គោលការណ៍ទីក្រុងប៉ារីស "

**<u>កត់សំគាល់</u> :** គោលការណ៍ស្ដីពីឋានៈនៃស្ថាប័នជាតិដើម្បីសិទ្ធិមនុស្ស ដែលគេស្គាល់ជាទូទៅថាជា "គោលការណ៍ទីក្រុងប៉ារីស" ពីព្រោះគោលការណ៍ទាំងនេះត្រូវបានផ្ដើមព្រាងឡើងនៅទីក្រុងប៉ារីស ។ គោលការណ៍នេះមិនជាប់ទាក់ទង និងមិនត្រូវភាន់ច្រឡំជាមួយកិច្ចព្រមព្រៀងសន្តិភាព ដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ ឡើយ : ច្បាប់ចុងក្រោយនៃសន្និសិទទីក្រុងប៉ារីស ស្ដីពីកម្ពុជា កិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួមមួយ នៃជម្លោះកម្ពុជា កិច្ចព្រមព្រៀងស្ដីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាពទឹកដី ភាពមិនអាចរំលោភបំពានបាន អព្យាក្រឹត្យភាព និងឯកភាពជាតិ នៃកម្ពុជា និងសេចក្ដីប្រកាសស្ដីពីការស្ដារនិងការកសាងប្រទេសកម្ពុជាឡើងវិញ។

*បោះពុម្ពផ្សាយដោយការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា*

*ខែ វិច្ឆិកា ឆ្នាំ ២០០៦*

# គោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិ
# ដើម្បីសិទ្ធិមនុស្ស

## អារម្ភកថា

គោលការណ៍ស្តីពី "ឋានៈនៃស្ថាប័នជាតិ" ត្រូវបាន អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣។ គោលការណ៍ទាំងនេះ ចែងអំពីលក្ខណៈវិច្ឆ័យជាមូលដ្ឋានក្នុងការកំណត់អំពីស្ថាប័នជាតិមួយសំរាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ហើយនិងកំណត់ថាតើស្ថាប័ននេះ មានប្រសិទ្ធភាព ឯករាជ្យភាព និងមានពហុនិយមយ៉ាងដូចម្តេចខ្លះ ?

គោលការណ៍ទាំងនេះចែកចេញជាបួនផ្នែក : ផ្នែកទីមួយពន្យល់អំពីសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នជាតិ ផ្នែកទីពីរ និយាយអំពីសមាសភាពរបស់ស្ថាប័នជាតិ និងការធា

នាឱ្យស្ថាប័ននេះមានឯករាជ្យភាព និងពហុនិយម ផ្នែកទីបី ចែងអំពីវិធីប្រតិបត្តិការរបស់ស្ថាប័នជាតិនេះ ហើយផ្នែកចុងក្រោយ
ចែងបន្ថែមគោលការណ៍មួយចំនួនពាក់ព័ន្ធនឹងស្ថាប័ន ដែលមានសមត្ថកិច្ចយុត្តាធិការប្រហាក់ប្រហែលគ្នា។

ស្ថាប័នជាតិដើម្បីសិទ្ធិមនុស្សនេះ នៅពេលដែលត្រូវបានបង្កើតឡើង ស្របតាមកាលៈទេសៈត្រឹមត្រូវ និងស្របតាមគោលការណ៍ទាំងនេះ ហើយអាចដើរតួនាទីដ៏សំខាន់ ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សដទៃទៀត។

ស្ថាប័នជាតិមានទម្រង់ផ្សេងៗគ្នាជាច្រើន។ ស្ថាប័នទាំងនេះ មានចាប់ពីគណៈកម្មការធំៗ ដែលមានសមាសភាព សមាជិកគណៈកម្មការឯករាជ្យ រហូតដល់សមាជិក ឬអ្នកការពារសិទ្ធិប្រជាពលរដ្ឋជាច្រើនរូប (ombodsmen) ស្ថាប័នជាតិអាច

មានសមត្ថកិច្ចផ្សេងៗគ្នា ៖
ស្ថាប័នជាតិខ្លះទទួលអំណាចយ៉ាងច្រើនក្នុងការស៊ើបអង្កេតនិងការដោះស្រាយករណីរំលោភសិទ្ធិមនុស្ស នៅក្នុងប្រទេសរបស់ខ្លួន ស្ថាប័នជាតិខ្លះមានអាណត្តិកំណត់ត្រឹមតែជាអ្នកផ្តល់អនុសាសន៍ដល់អាជ្ញាធរមានសមត្ថកិច្ចឬធ្វើយ៉ាងណាឱ្យសាធារណជនយល់ដឹងច្រើនថែមទៀតអំពីបញ្ហាសិទ្ធិមនុស្សតាមរយៈការអប់រំ ការស្រាវជ្រាវ និងការផ្សព្វផ្សាយព័ត៌មានផ្សេងៗ។

ទោះជាមានសមាសភាព សមត្ថកិច្ច ឬវិធីប្រតិបត្តិការដូចម្តេចក៏ដោយ ស្ថាប័នទាំងនេះ ត្រូវបានគេចាត់ថ្នាក់ថាជាស្ថាប័នជាតិដើម្បីសិទ្ធិមនុស្ស។ គេបង្កើតស្ថាប័នជាតិទាំងនេះឡើង ក្នុងបំណងអនុវត្តការទទួលខុសត្រូវរបស់រដ្ឋ ដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានការពារ និងគោរព ហើយកិច្ចការដំបូងនិងសំខាន់ជាងគេបំផុតនោះ គឺឯករាជ្យភាពនៃតុលាការ។ ស្ថាប័នទាំងនេះក៏អាចដើរតួនាទីជា "ស្ពាន" មួយដ៏សំខាន់រវាងរដ្ឋាភិបាល និងសង្គមស៊ីវិលផងដែរ។

ស្ថាប័នជាតិទាំងនេះ អាចដំណើរការប្រកបដោយប្រសិទ្ធភាពទៅបាន លុះត្រាតែឯករាជ្យពីរដ្ឋាភិបាល និងមានពហុនិយមនៃសមាជិកភាពរបស់ខ្លួន ដែលតំណាងឱ្យគ្រប់វិស័យទាំងអស់នៃសង្គម។ស្ថាប័នមួយដែលស្របទៅនឹងគោលការណ៍ទាំងនេះ អាចមានឱកាសច្រើនក្នុងការសំរេចបាននូវគោលដៅរបស់ខ្លួនក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្សនៅថ្នាក់ជាតិ។

## <u>គោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិនានា</u>

សេចក្តីសំរេចអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលេខ A/RES/48/134 ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៤

## សមត្ថកិច្ច និងការទទួលខុសត្រូវ

១- ស្ថាប័នជាតិមួយត្រូវមានសមត្ថកិច្ចក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស។

២- ស្ថាប័នជាតិមួយ ត្រូវបានផ្តល់អាណត្តិយ៉ាងទូលំទូលាយតាមដែលអាចធ្វើបានដែលនឹងត្រូវបានចែងយ៉ាងច្បាស់នៅក្នុងអត្ថបទរដ្ឋធម្មនុញ្ញ ឬអត្ថបទច្បាប់ ដោយគូសបញ្ជាក់អំពីសមាសភាព និងវិសាលភាពនៃសមត្ថភាពរបស់ខ្លួន។

៣- ស្ថាប័នជាតិមួយត្រូវមានការទទួលខុសត្រូវ <u>ក្នុងនោះ</u>មានការទទួលខុសត្រូវដូចខាងក្រោមនេះ :

(<u>ក</u>) ដាក់ស្នើទៅរដ្ឋាភិបាល សភាជាតិ និងស្ថាប័នមាន

សមត្ថកិច្ចដទៃទៀត ដោយឈរលើមូលដ្ឋាន នៃការប្រឹក្សាយោបល់ តាមរយៈការស្នើសុំពីអាជ្ញាធរពាក់ព័ន្ធ ឬតាមរយៈការប្រើប្រាស់អំណាចរបស់ខ្លួនក្នុងការបើកសវនាការលើបញ្ហាណាមួយ ដោយមិនចាំបាច់បញ្ជូនទៅថ្នាក់លើនូវមតិ យោបល់ អនុសាសន៍ សំណើ និងរបាយការណ៍ពីបញ្ហាអ្វីមួយពាក់ព័ន្ធនឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ស្ថាប័នជាតិ អាចសំរេចធ្វើការបោះពុម្ពផ្សាយព័ត៌មានទាំងនោះ មតិ យោបល់ អនុសាសន៍ សំណើ និងរបាយការណ៍ទាំងនេះ ក៏ដូចជាបុព្វសិទ្ធិរបស់ស្ថាប័នជាតិ ត្រូវតែទាក់ទងទៅនឹងវិស័យដូចខាងក្រោមនេះ :

(១) បញ្ញត្តិច្បាប់ ឬបញ្ញត្តិរដ្ឋបាលក៏ដូចជាបញ្ញត្តិទាំងឡាយដែលទាក់ទងនឹងអង្គការតុលាការ ដែលមានបំណងរក្សា និងពង្រឹងការការពារសិទ្ធិមនុស្ស ចំពោះបញ្ហានេះ ស្ថាប័នជាតិត្រូវពិនិត្យបញ្ញត្តិច្បាប់ និងបញ្ញត្តិរដ្ឋបាលដែលនៅជាធរមានក៏ដូចជាច្បាប់ និងសំណើផ្សេងៗ ហើយត្រូវផ្តល់អនុសាសន៍

ទាំងនេះតាមការគួរ ដើម្បីធានាឱ្យបទបញ្ញត្តិទាំងនេះស្របទៅនឹងគោលការណ៍ជាមូលដ្ឋានស្តីពីសិទ្ធិមនុស្ស បើសិនជាចាំបាច់ ស្ថាប័ននេះ ស្នើសុំឱ្យអនុម័តច្បាប់ថ្មី ឬធ្វើវិសោធនកម្មច្បាប់ដែលកំពុងអនុវត្ត និងអនុម័ត ឬធ្វើវិសោធនកម្មវិធានរដ្ឋបាល

ផ្សេងៗ ។

(២) ស្ថានភាពណាមួយ នៃការរំលោភសិទ្ធិមនុស្ស ដែលខ្លួនសំរេចទទួលដោះស្រាយ ។

(៣) ការរៀបចំរបាយការណ៍ ស្តីពី ស្ថានការណ៍ជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្សទូទៅ និងបញ្ហាជាក់លាក់ដទៃទៀត ។

(៤) ទាញចំណាប់អារម្មណ៍របស់រដ្ឋាភិបាល ចំពោះសភាព-ការណ៍ផ្សេងៗ នៅក្នុងតំបន់ណាមួយនៃប្រទេស ដែលមានការរំលោភសិទ្ធិមនុស្ស និងធ្វើសំណើទៅរដ្ឋាភិបាលសុំឱ្យផ្តើមគំនិតដើម្បីបញ្ឈប់សភាពការណ៍ទាំងនោះ ហើយប្រសិនជាចាំបាច់

ត្រូវសំដែងមតិយោបល់អំពីជំហ និងប្រតិកម្មចំពោះរដ្ឋាភិបាល

(ខ) លើកស្ទួយ និងធានាឱ្យមានភាពស្របគ្នារវាងច្បាប់បទបញ្ជា និងការអនុវត្តន៍ថ្នាក់ជាតិ ជាមួយនឹងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលរដ្ឋគឺជាភាគី និងការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តទាំងនោះឱ្យមានប្រសិទ្ធភាព ។

(គ) ជំរុញឱ្យមានការផ្តល់សច្ចាប័នលើលិខិតុបករណ៍ទាំងឡាយ ដែលបានរៀបរាប់ខាងលើ ឬការចូលជាសមាជិកនៃលិខិតុបករណ៍ទាំងនោះ ហើយត្រូវធានាការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តទាំងនោះ ។

(ឃ) រួមចំណែកក្នុងការធ្វើរបាយការណ៍ ដែលរដ្ឋជាភាគីត្រូវបានតម្រូវឱ្យដាក់របាយការណ៍នេះ ទៅស្ថាប័ន និងគណៈកម្មាធិការទាំងឡាយ របស់អង្គការសហប្រជាជាតិ និងទៅស្ថាប័ននានានៅថ្នាក់តំបន់ ស្របតាមកាតព្វកិច្ចនៃសន្ធិសញ្ញារបស់ខ្លួន ហើយប្រសិនជាចាំបាច់ ត្រូវសំដែងមតិ យោបល់លើ

ប្រធានបទ ដោយគោរពឱ្យបានត្រឹមត្រូវចំពោះឯករាជ្យភាពរបស់ខ្លួន។

(ង) សហការណ៍ជាមួយអង្គការសហប្រជាជាតិ និងអង្គការដទៃទៀត នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ស្ថាប័នថ្នាក់តំបន់ និងស្ថាប័នថ្នាក់ជាតិនៃប្រទេសដទៃទៀតដែលមានសមត្ថកិច្ចក្នុងវិស័យការពារ និងលើកស្ទួយសិទ្ធិមនុស្ស។

(ច) ជួយបង្កើតកម្មវិធីសំរាប់បង្រៀននិងសំរាប់ការស្រាវជ្រាវអំពីសិទ្ធិមនុស្ស និងរួមចំណែកក្នុងការបង្ហាត់បង្រៀននៅតាមសាលារៀន សាកលវិទ្យាល័យ និងភូមិសិក្សាវិជ្ជាជីវៈផ្សេងៗ។

(ឆ) ធ្វើការផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស និងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើង ជាពិសេសការរើសអើងពូជសាសន៍ ដោយបង្កើនការយល់ដឹង ដល់សាធារណៈជន ជាពិសេសតាមរយៈព័ត៌មាន និងការអប់រំ និងតាម-

រយៈការប្រើប្រាស់ទីភ្នាក់ងារសារព័ត៌មានទាំងអស់។

## សមាសភាព និងការធានាឯករាជ្យភាព និងពហុនិយម

(១) សមាសភាពរបស់ស្ថាប័នជាតិ និងការតែងតាំងសមាជិករបស់ខ្លួន ទោះជាតាមមធ្យោបាយនៃការបោះឆ្នោតជ្រើសតាំង ឬតាមមធ្យោបាយផ្សេងពីនេះ ត្រូវតែបានបង្កើតឡើងស្របទៅតាមនីតិវិធីមួយដែលលៃលក រាល់ការធានាដែលចាំបាច់ដើម្បីបញ្ជាក់ពីភាពជាតំណាងអោយពហុភាពនិយមនៃកំលាំងសង្គម(នៃសង្គមស៊ីវិល) ដែលពាក់ព័ន្ធក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស ជាពិសេស តាមរយៈអំណាចផ្សេងៗដែលនឹងអាចបង្កើតឱ្យមានកិច្ចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងតំណាង ឬតាមរយៈវត្តមានតំណាងរបស់:

(ក) អង្គការក្រៅរដ្ឋាភិបាលដែលទទួលខុសត្រូវផ្នែកសិទ្ធិ មនុស្ស និង-ការខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងនឹងការ រើសអើង-

ពុជសាសន៍ សហជីព អង្គការសង្គម និងវិជ្ជាជីវៈដែលពាក់ព័ន្ធ ឧទាហរណ៍ សមាគមមេធាវី វេជ្ជបណ្ឌិត អ្នកសារព័ត៌មាន និងសមាគមអ្នកវិទ្យាសាស្ត្រជាន់ខ្ពស់ទាំងឡាយជាដើម។

(ខ) មាននិន្នាការទៅរកគំនិតខាងទស្សនះវិជ្ជា ឬខាងសាសនា

(គ) សកលភាព និងអ្នកជំនាញដែលមានគុណសម្បត្តិគ្រប់គ្រាន់

(ឃ) សភាជាតិ

(ង) ក្រសួងនានារបស់រដ្ឋាភិបាល(ប្រសិនជាត្រូវបានរាប់បញ្ចូល តំណាងទាំងនេះ គួរតែចូលរួមត្រឹមតែការពិភាក្សាប៉ុណ្ណោះ ក្នុងសមត្ថកិច្ចជាអ្នកផ្តល់ប្រឹក្សាយោបល់)។

២-ស្ថាប័នជាតិ ត្រូវមានហេត្ថារចនាសម្ព័ន្ធ ដែលសក្តិសមទៅនឹងការធ្វើសកម្មភាពដំរលូនរបស់ខ្លួន ជាពិសេស ត្រូវមាន

ថវិកាគ្រប់គ្រាន់។ គោលបំណងនៃថវិកានេះគួរតែធ្វើឱ្យស្ថាប័ននេះ មានបុគ្គលិកនិងទីតាំងផ្ទាល់ខ្លួន ដើម្បីឱ្យមានភាពឯករាជ្យ ពីរដ្ឋាភិបាល ហើយមិនស្ថិតក្រោម-ការគ្រប់គ្រងហិរញ្ញវត្ថុពី រដ្ឋាភិបាលដែលអាចនាំឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ខ្លួន។

៣- ដើម្បីធានាឱ្យមានអាណត្តិមួយដែលមានស្ថេរភាពសំរាប់សមាជិកនៃស្ថាប័នជាតិនេះ បើពុំនោះទេស្ថាប័ននេះ នឹងមិនអាចមានឯករាជ្យភាពពិតប្រាកដឡើយ ការតែងតាំងសមាជិកត្រូវតែធ្វើឡើងដោយច្បាប់មួយជាធរមានដែលនឹងត្រូវកំណត់រយៈពេលជាក់លាក់នៃអាណត្តិនេះ។ អាណត្តិនេះ អាចនឹងបន្តទៀតបានដរាបណាពហុភាពនិយមនៃស្ថាប័ននេះត្រូវតែធានា។

## វិធីសាស្ត្រនៃប្រតិបត្តិការ

ស្ថិតនៅក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរបស់ខ្លួន ស្ថាប័នជាតិនេះត្រូវ :

(ក) ពិចារណាដោយសេរីនូវបញ្ហាទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ទោះជាបញ្ហានោះត្រូវបានបញ្ជូនដោយរដ្ឋាភិបាល ឬស្ថាប័ននេះបានទទួលយក ដោយមិនមានការបញ្ជូនទៅអាជ្ញាធរថ្នាក់លើតាមសំណើររបស់សមាជិកខ្លួន ឬដោយអ្នកប្តឹងណាម្នាក់ក៏ដោយ ។

(ខ) ស្តាប់ជនណាក៏ដោយ និងទទួលព័ត៌មាននិងឯកសារណាក៏ដោយដែលចាំបាច់ សំរាប់ធ្វើការវាយតំលៃសភាពការណ៍ទាំងឡាយដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

(គ) ឆ្លើយតបចំពោះមតិយោបល់របស់សាធារណៈដោយផ្ទាល់ ឬតាមរយៈអង្គការសារព័ត៌មាន ជាពិសេសដើម្បីធ្វើការផ្សព្វផ្សាយមតិយោបល់ និងអនុសាសន៍របស់ខ្លួន ។

(ឃ) ជួបប្រជុំជាប្រចាំ និងតាមការចាំបាច់ នៅចំពោះវត្តមាននៃសមាជិកទាំងអស់របស់ខ្លួន បន្ទាប់ពីមានការកោះប្រជុំយ៉ាងត្រឹមត្រូវនោះ ។

(ង) បង្កើតក្រុមការងារពីក្នុងចំណោមសមាជិករបស់ខ្លួន តាមការចាំបាច់ ហើយបង្កើតផ្នែកផ្សេងៗ តាមមូលដ្ឋាន ឬ តាមតំបន់ ដើម្បីជួយដល់ស្ថាប័ននេះ ក្នុងការអនុវត្តនីមុខងារ ភារកិច្ចរបស់ខ្លួន។

(ច) ធ្វើការពិគ្រោះយោបល់ ជាមួយស្ថាប័នដទៃទៀត ទោះជាស្ថាប័នតុលាការ ឬស្ថាប័នផ្សេងពីនេះក៏ដោយ ដែលទទួលខុសត្រូវក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស (ជាពិសេស ការិយាល័យប្រជាពលរដ្ឋ និងស្ថាប័នប្រហាក់ប្រហែលដទៃទៀត)។

(ឆ) តាមទស្សនៈដែលថា អង្គការក្រៅរដ្ឋាភិបាលនានា-បានដើរតួយ៉ាងសំខាន់ក្នុងការពង្រីកការងាររបស់ស្ថាប័នជាតិ ស្ថាប័ននេះបង្កើតទំនាក់ទំនងកាន់តែច្រើនឡើងជាមួយអង្គការក្រៅរដ្ឋាភិបាលដែលបានលះបង់ចំពោះការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ការប្រយុទ្ធប្រឆាំងពូជសាសន៍និយម ការការពារពិសេសដល់ក្រុម

ជនដែលងាយរងគ្រោះ (ជាពិសេសកុមារ កម្មករទេសន្តរប្រវេសន៍ ជនភៀសខ្លួន ជនពិការផ្លូវកាយនិងផ្លូវចិត្ត) ឬចំពោះវិស័យឯកទេសផ្សេងៗទៀត។

## គោលការណ៍បន្ថែមស្តីពីឋានៈនៃគណៈកម្មការនានា ដែលមានសមត្ថកិច្ចដូចតុលាការ

ស្ថាប័នជាតិមួយអាចមានសិទ្ធិអំណាចក្នុងការធ្វើសវនាការ និងពិចារណាលើបណ្តឹង និងញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងស្ថានភាពបុគ្គល។ ករណីរឿងទាំងឡាយនៅចំពោះមុខខ្លួនដែលប្តឹងដោយបុគ្គល អ្នកតំណាង ឬតតិយជន អង្គការក្រៅរដ្ឋាភិបាល សមាគមសហជីពកម្មករ ឬអង្គការតំណាងដទៃទៀត។ នៅក្នុងករណីនេះ និងដោយមិនប៉ះពាល់ដល់គោលការណ៍ ដែលមានចែងខាងលើស្តីពីអំណាចដទៃទៀតរបស់គណៈកម្មការ មុខងារដែលបានប្រគល់ឱ្យគណៈកម្មការទាំងនេះ ត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោមនេះ:

(ក) ស្វែងរកដំណោះស្រាយមួយប្រកបដោយមេត្រីភាព តាមរយៈការផ្សះផ្សា ឬស្ថិតក្នុងក៏រិតដែលបានកំណត់ដោយច្បាប់តាមរយៈសេចក្តីសំរេចជាធរមាននានា ឬប្រសិនបើចាំបាច់ត្រូវផ្អែកលើមូលដ្ឋាននៃការរក្សាការសំងាត់ ។

(ខ) ជូនដំណឹងទៅភាគីដែលប្តឹងតវ៉ាពីសិទ្ធិរបស់ខ្លួន ជាពិសេស ដំណោះស្រាយដែលមានចំពោះគាត់ និងការលើក-ស្ទួយពួកគាត់អោយទទួលបានសិទ្ធិទាំងនោះ ។

(គ) បើកសវនាការលើបណ្តឹង ឬញត្តិ ឬបញ្ជូនបណ្តឹង ឬញត្តិនោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត តាមការកំណត់ដូចមានចែងនៅក្នុងច្បាប់ ។

(ឃ) ផ្តល់អនុសាសន៍ ទៅអាជ្ញាធរមានសមត្ថកិច្ច ជាពិសេស ដោយការស្នើធ្វើវិសោធនកម្ម ឬធ្វើកំណែទម្រង់ច្បាប់ បទបញ្ជា និងការអនុវត្តន៍មួយចំនួនផ្អែករដ្ឋបាល ជាពិសេស ប្រសិនបើការអនុវត្តន៍នោះ បានបង្កការលំបា